00323168

D158/5/4/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ ១៩ |
| **បញ្ជូនទៅ:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃការបញ្ជូន** | ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ |
| **ភាគីបញ្ជូន:** | សហមេធាវីការពារក្តីអន្តរជាតិ អ្នកស្រី អៀង ធីរិទ្ធ |
| **ភាសាដើម:** | ភាសាអង់គ្លេស និង ភាសាខ្មែរ(បកប្រែ) |
| **ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** | សាធារណៈ |

---

**បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ"ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត**

---

<u>បញ្ជូនដោយ៖</u>

**សហមេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**

កញ្ញា Diana ELLIS QC

<u>អ្នកទទួលឯកសារ:</u>

**អង្គបុរេជំនុំជម្រះ:**

ប្រាក់ គឹមសាន, ប្រធាន

ហ៊្វីត វុទ្ធី

Rowan DOWNING

ន៉ីយ ថុល

Katinka LAHUIS

ប៉ែន ពេជ្រសាលី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 05 / 2009
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារដើមត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Tuy

## I. សេចក្តីផ្តើម និង ច្បាប់

1. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ មេធាវីការពារក្តី លោក នួន ជា បានដាក់ "សំណើសុំលើកទី១១ដើម្បីបំពេញកិច្ចស៊ើបសួរ" ហៅថា("សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១")[1] ដែលបានស្នើសុំការិយាល័យសហចៅក្រមស៊ើបអង្កេត ហៅថា"ក.ស.ច.ស"ដើម្បីយករបាយការណ៍OIOS និងបញ្ចេញឲ្យដឹងនូវព័ត៌មានដែលមានក្នុងរបាយការណ៍នោះ ព្រមទាំងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធឲ្យដល់មេធាវីការពារក្តី ។

2. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ បានដាក់ញត្តិមួយនៅក្នុងការគាំទ្រទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១ខាងលើនេះ ("ញត្តិគាំទ្ររបស់អ្នកស្រី អៀង ធីរិទ្ធ")[2]។ មេធាវីការពារក្តី លោក អៀង សារី និង លោក ខៀវ សំផន បានដាក់ញត្តិស្រដៀងគ្នានេះដែរនៅក្នុងការគាំទ្រចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១នេះ[3] ។

3. ក.ស.ច.ស បានចេញ "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ហៅថា ("ដីកា")ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ ដែលបានបដិសេធសំណើសុំ និងញត្តិគាំទ្រទាំងឡាយ។

4. អនុលោមតាមវិធានផ្ទៃក្នុង៧៥(១)ៈ មេធាវីការពារក្តី លោក នួន ជាបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនោះ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៩[4] ។ សេចក្តីជូនដំណឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដោយមេធាវីការពារក្តី លោក ខៀវ សំផន, លោក អៀង សារី និង អ្នកស្រី អៀង ធីរិទ្ធ[5] ។

5. ហេតុដូច្នេះ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ(ចាប់ពីពេលនេះតទៅហៅថា "ម្ចាស់បណ្តឹងឧទ្ធរណ៍") សូមដាក់សារណាស្តីពីបណ្តឹងឧទ្ធរណ៍ដោយអនុលោមតាមវិធានផ្ទៃក្នុង ៧៥(៣)។

---

[1] សំណើសុំលើកទី១១ដើម្បីបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ D158 ។

[2] ញត្តិគាំទ្រចំពោះសំណើសុំលើកទី១១ដើម្បីបំពេញកិច្ចស៊ើបសួរសំរាប់ការបញ្ចេញឲ្យដឹងនូវរបាយការណ៍ OIOS និងឯកសារដែលពាក់ព័ន្ធ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខៈD158/3 ។

[3] ញត្តិរបស់លោក អៀង សារី ដើម្បីចូលរួម និងយកនូវសំណើសុំលើកទី១១ដើម្បីបំពេញកិច្ចស៊ើបសួររបស់នួន ជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខៈD158/2, និងសេចក្តីថ្លែងការណ៍របស់ក្រុមមេធាវីការពារក្តីដើម្បីឲ្យទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរលើលទី១១របស់ នួន ជា ដែលទាក់ទងនឹងការចោទប្រកាន់អំពីបទពុករលួយនៅ អ.វ.ត.ក ។

[4] កំណត់ហេតុចុះពាក្យបណ្តឹងឧទ្ធរណ៍របស់ នួន ជា ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខៈ D158/5/1

[5] កំណត់ហេតុចុះពាក្យបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០០៩,ឯកសារលេខៈD158/5/2។ កំណត់ហេតុចុះពាក្យបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩, ឯកសារលេខៈ D158/5/3 និងកំណត់ហេតុចុះពាក្យបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩, ឯកសារលេខៈ D158/5/4។

II. **អំណះអំណាង**

6. ហេតុដូច្នេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍សូមដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍សូមយកតាមអំណះអំណាងដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ លោក នួន ជា ។

III. **សំណូមពរ**

7. សំរាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្ដី សូមលើកឡើងថា ការបដិសេធសំណើបំពេញកិច្ចស៊ើបសួរលើកទី១១របស់ ក.ស.ច.ស គឺមិនត្រឹមត្រូវដោយសំអាងលើបញ្ហាច្បាប់, គោលនយោបាយសាធារណៈ និងសុភវិនិច្ឆ័យ។ អាស្រ័យហេតុនេះ អ.ជ.ប គួរតែចាត់ទុកជាមោឃៈដីកាសម្រេចនោះ និងផ្ដល់ដំណោះស្រាយដែលបានស្នើសុំនៅក្នុងកថាខណ្ឌទី ២២ នៃសំណើសុំលើកទី១១។ លើសពីនេះទៀតនោះ ដោយសារតែបណ្ដឹងឧទ្ធរណ៍របស់ នួន ជា មិនមានឯកសារសម្ងាត់ ហេតុនេះ អ.ជ.ប គួរតែចាត់ថ្នាក់ឯកសារនេះជាសាធារណៈ។ ជាចុងក្រោយ យើងស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈនៅពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩។

p/p

កញ្ញា Diana ELLIS, QC

សហមេធាវីការពារក្ដីអន្តរជាតិរបស់ អ្នកស្រី អៀង ធីរិទ្ធ